# សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
ស.ទ.ក
C.W.A
Cambodian Water Supply Association

## អំពីសមាគម

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជាគឺជាសមាគមអព្យាក្រឹតមិនស្វែងរកប្រាក់កម្រៃជាឯកជន មិនប្រកាន់ពូជសាសន៍ មិនប្រកាន់ សាសនា មិនប្រកាន់និន្នាការនយោបាយ មិនធ្វើនយោបាយ។ សមាគមបង្កើត ឡើងនៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១១ និងបានចុះបញ្ជីនៅក្រសួងមហាផ្ទៃនៅថ្ងៃទី៦ ខែសីហា ឆ្នាំ២០១២ និងចុះឈ្មោះឡើងវិញក្នុងបញ្ជីសមាគមសម្រាប់នីតិបុគ្គលនៅក្រសួងមហាផ្ទៃ ថ្ងៃទី៨ ខែ វិច្ឆិកា ឆ្នាំ២០២១។ សមាគមបង្កើតក្នុងគោលបំណង «ប្រមូលផ្តុំអ្នករួមអាជីព ឬរួមវិជ្ជាជីវៈទាំងអស់ក្នុងវិស័យផ្គត់ផ្គង់ទឹកស្អាតនៅព្រះរាជាណាចក្រកម្ពុជា»។ គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០២៥ សមាគមមានសមាជិកចំនួន ៣៤២ (២៨៦ ស្ថានីយ) កំពុងប្រតិបត្តិការក្នុង ២៣រាជធានី-ខេត្ត។

## តួនាទីចម្បងៗរបស់សមាគម

- លើកកម្ពស់សេវាកម្មផ្តោតលើសមាជិក
- ធ្វើជាតំណាង និងស្វែងរកការគាំទ្រមតិ
- ពង្រឹង និងពង្រីកកិច្ចសហការរវាងភាគីពាក់ព័ន្ធ និងភាពជាដៃគូ
- កសាងសមត្ថភាព និងអភិវឌ្ឍវិជ្ជាជីវៈ
- សម្របសម្រួលលទ្ធភាពទទួលបានហិរញ្ញវត្ថុ
- គាំទ្រផ្នែកច្បាប់ និងបទប្បញ្ញត្តិ
- បង្កើនការយល់ដឹង និងការចូលរួមរបស់សហគមន៍
- លើកកម្ពស់នវានុវត្តន៍ ភាពធន់ និងនិរន្តរភាព




## ដៃគូយុទ្ធសាស្ត្រ

SME BANK
CGCC
I.T.C.
informa markets
KOWBA
AUSTRALIAN WATER ASSOCIATION
SWA Singapore Water Association

## ម្ចាស់ជំនួយ

water.org
Australian Aid
CAPRED

## អាសយដ្ឋាន

មជ្ឈមណ្ឌលភ្នំពេញ អគារF ជាន់ទី២ បន្ទប់២៦៩ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទទំនាក់ទំនង៖ 017 799 337
070 799 337
097 717 9943

info@cwa.org.kh
www.facebook.com/cwa.org.kh
Cambodian Water Supply Association (CWA)
CWA Water Association
www.cwa.org.kh



## ទឹកស្អាតសម្រាប់ទាំងអស់គ្នា



## ទស្សនៈវិស័យ

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ចង់ឃើញប្រជាពលរដ្ឋកម្ពុជានៅគ្រប់តំបន់ក្នុងព្រះរាជាណាចក្រកម្ពុជាទទួលបានសេវាទឹកស្អាត និងអនាម័យ ដែលមានគុណភាពស្របតាមស្តង់ដាថ្នាក់ជាតិ។

## បេសកកម្ម

១. គាំទ្រ និងលើកកម្ពស់ការជួយគ្នាទៅវិញទៅមករវាងអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា
២. បង្កើនចំណេះដឹង បច្ចេកទេសស្របតាមស្តង់ដាទឹកស្អាតថ្នាក់ជាតិ និង
៣.ជំរុញឱ្យមាននិរន្តរភាពនិងការពង្រីកសេវាកម្មផ្គត់ផ្គង់ទឹកស្អាតនៅកម្ពុជា។







## ដើម្បីចូលជាសមាជិកអាជីព

- ជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលទទួលបានប្រកាសអនុញ្ញាតឱ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតពីក្រសួង ឧ.វ.ប.ន
- ស្ម័គ្រចិត្តដាក់ពាក្យសុំចូលជាសមាជិកអាជីព និងបំពេញកាតព្វកិច្ចសមាជិក ដោយភ្ជាប់មកជាមួយនូវប្រកាសអនុញ្ញាត រូបថត(៤x៦) និងអត្តសញ្ញាណប័ណ្ណ
- យល់ព្រមឱ្យចូលជាសមាជិកអាជីព ពីក្រុមប្រឹក្សាភិបាល
- បង់វិភាគទានសមាជិកភាពសម្រាប់មួយឆ្នាំយ៉ាងតិច។

## ដើម្បីចូលជាសមាជិកគាំទ្រ

- ជារូបវន្តបុគ្គលឬនីតិបុគ្គលដែលជាអ្នកពាក់ព័ន្ធក្នុងវិស័យទឹកស្អាតនៅកម្ពុជា
- ស្ម័គ្រចិត្តដាក់ពាក្យសុំចូលជាសមាជិកគាំទ្រ និងបំពេញកាតព្វកិច្ចសមាជិកដោយភ្ជាប់មកជាមួយនូវប័ណ្ណប៉ាតង់ ឬលិខិតអនុញ្ញាឱ្យបើកស្ថាប័ន រូបថត(៤x៦) និងអត្តសញ្ញាណប័ណ្ណ
- យល់ព្រមឱ្យចូលជាសមាជិកគាំទ្រ ពីក្រុមប្រឹក្សាភិបាល
- បង់វិភាគទានសមាជិកភាពសម្រាប់មួយឆ្នាំយ៉ាងតិច។



## អត្ថប្រយោជន៍សមាជិក

- រួមគ្នាស្វែងរកមតិគាំទ្រ ដើម្បីប្រយោជន៍សមាជិក និងវិស័យទឹកស្អាត
- ទទួលបានការពិគ្រោះយោបល់ និងដោះស្រាយបញ្ហា
- ទទួលបានវគ្គបណ្តុះបណ្តាលលើបច្ចេកទេស និងការគ្រប់គ្រងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត
- ទទួលបានព័ត៌មាន ចំណេះដឹង និងបទពិសោធន៍ទាក់ទងនឹងវិស័យទឹកស្អាត
- មានអាទិភាពទទួលបានកម្ចីដែលមានអត្រាការប្រាក់ទាបពីស្ថាប័នហិរញ្ញវត្ថុជាដៃគូសមាគម
- កសាងទំនាក់ទំនង និងធុរកិច្ចក្នុងវិស័យទឹកស្អាត
- ទទួលបានការគាំទ្រពីក្រសួងឧ.វ.ប.ន.និងអ្នកពាក់ព័ន្ធតាមរយៈការសម្របសម្រួលរបស់សមាគម
- ទទួលបានឱកាសទស្សនកិច្ចក្នុង និងក្រៅប្រទេស
- ទទួលបានការបញ្ចុះតម្លៃលើកម្មវិធី និងសេវាកម្មរបស់សមាគម និងដៃគូ
- អាចធ្វើការផ្សព្វផ្សាយផលិតផល និងឱកាសការងារលើប្រព័ន្ធផ្សព្វផ្សាយរបស់សមាគម